គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៤៤១៣៤៤៣/អ.គ.គ.ក

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ..មីនា... ឆ្នាំ២០១៣

**គោរពជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

__កម្មវត្ថុ__ ៖ការរៀបចំកិច្ចព្រមព្រៀងស្តីពីការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០១៣រវាងរដ្ឋបាលរាជធានី ខេត្តនិងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

__យោង__ ៖ ផែនការសកម្មភាព និងថវិកាផអ៣ ឆ្នាំ២០១៣ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ របស់គ.ជ.អ.ប។
-សៀវភៅណែនាំស្តីពីការរៀបចំនិងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា ជារៀងរាល់ឆ្នាំ គ.ជ.អ.ប បានគាំទ្រថវិកាមួយចំនួនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត សម្រាប់គាំទ្រដល់ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងាររៀបចំការគ្រប់គ្រងនិងអភិវឌ្ឍន៍សមត្ថភាព ផ្អែកតាមផែនការអនុវត្តរយៈពេល៣ឆ្នាំនៃកម្មវិធីជាតិដែលក្នុងមួយក្រុង ស្រុកអាចទទួលថវិកាតិចឬច្រើនអាស្រ័យលើសកម្មភាពដែលគាំទ្រដោយប្រភពមូលនិធិនានាដូចជាមូលនិធិជាកញ្ចប់ (UN-women និង UNICEF) ជាដើម ។

ជាក់ស្តែងក្នុងឆ្នាំ២០១៣នេះថវិកាសម្រាប់គាំទ្រដល់ការអនុវត្តន៍របស់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌមួយចំនួនដែលមិនមានថវិកាគាំទ្របន្ថែមពីគម្រោង UN-women និងកម្មវិធីសិទ្ធកុមារអង្គការ UNICEF ទទួលបានថវិកាជាមធ្យមគឺពី៥០០ ទៅ៦០០ដុល្លារអាមេរិកប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ ដើម្បីជួយសម្រួលដល់ការរៀបចំនិងការអនុវត្តផ.ស.ថឆ្នាំ២០១៣ របស់ក្រុង ស្រុក ខណ្ឌ លេខាធិការដ្ឋានគ.ជ.អ.បអនុញ្ញាតអោយក្រុង ស្រុក ខណ្ឌដែលមិនទទួលបានថវិកាបន្ថែមពី UN-women និង UNICEF ពុំចាំបាច់រៀបចំកិច្ចព្រមព្រៀងផ.ស.ថឆ្នាំ២០១៣ រវាងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌឡើយ ក្រុង ស្រុកទាំងនោះអាចស្នើសុំបុរេប្រទានថវិកាផ្ទាល់ពីរាជធានី ខេត្ត ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួន។ ចំពោះក្រុង ស្រុក ដែលទទួលបានការគាំទ្រមូលនិធិបន្ថែមពី UN-women និង UNICEF ត្រូវរៀបចំកិច្ចព្រមព្រៀងរវាងខេត្ត និងក្រុង ស្រុកស្របតាមនិតិវិធីនិងទម្រង់បែបបទដែលបានកំណត់ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ជ. **ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប**

**ង៉ាន់ ចំរើន**

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038